# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប២៥ឆ្នាំនៃបេកកម្មបងស្រីមេត្តាករុណាចោមចៅ
# ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៨

*យើងត្រូវមានទឹកចិត្តដូចម្ដាយជានិច្ច*

អត្ថបទទី១៖ រម ១០,៩-១៨
ដំណឹងល្អ៖ មថ ៩,១៨-២២

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីមួយ "**ខ្ញុំសូមរំឭកអំពីអំពើដ៏សប្បុរសរបស់ព្រះជាម្ចាស់ ខ្ញុំសរសើរតម្កើងព្រះជាម្ចាស់ចំពោះកិច្ចទាំងប៉ុន្មានដែលព្រះអង្គបានប្រព្រឹត្តមកលើយើង**" ណែនាំឲ្យយើងចូលពិធីអរព្រះគុណ២៥ឆ្នាំ ដែលបងស្រីមេត្តាករុណាមានវត្តមាននៅចោមចៅ។ អរគុណលោក តូនី ដែលបានណែនាំឲ្យបងស្រីមានការណែនាំខាងផ្លូវវិញ្ញាណតាំងពីដើមរហូតដល់ពេលនេះ។ យើងនឹកឃើញដល់២៥ឆ្នាំ មិនមែនដើម្បីលើកតម្កើងនិងសរសើរយើងផ្ទាល់ ប៉ុន្តែដើម្បីលើកតម្កើងនិងសរសើរព្រះជាម្ចាស់ ដោយនឹកឃើញអ្វីៗទាំងអស់ដែលយើងអាចធ្វើទៅបាន អ្វីៗទាំងអស់ដែលយើងបានប្រព្រឹត្តនៅក្នុង២៥ឆ្នាំកន្លងមក គឺដោយសារព្រះជាម្ចាស់គង់នៅ ព្រះជាម្ចាស់ជម្រុញ ព្រះជាម្ចាស់ផ្ដល់កម្លាំង ព្រះជាម្ចាស់ធ្វើដំណើរជាមួយយើង និងជាពិសេសដោយសារយើងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ជាមូលហេតុថ្ងៃនេះ បងស្រីបានរើសអត្ថបទមង្គលការនៅកាណា ដោយនឹកឃើញដល់ព្រះនាងម៉ារីដែលបាននិយាយទៅអ្នកបម្រើថា "**បើលោកប្រាប់ឲ្យធ្វើអ្វី ចូរធ្វើតាមទៅ**" សូមធ្វើតាមអ្វីដែលព្រះយេស៊ូនិយាយ។

ថ្ងៃនេះដែលយើងបានប្រារព្ធ២៥ឆ្នាំ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់អ្នកម្ដាយតេរេសាដែលបានឡើងស្ថានបរមសុខហើយ ជាសន្តិមួយរូបដែលបំភ្លឺនិងណែនាំតទៅទៀតជីវិតរបស់បងស្រី និងជីវិតរបស់យើង ដើម្បីយកចិត្តទុកដាក់សម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ នៅក្នុងអត្ថបទទីមួយ "**ព្រះអង្គបានលោះពួកគេដោយព្រះហឫទ័យស្រឡាញ់ និងព្រះហឫទ័យមេត្តាករុណា**" មានន័យថាបងប្អូនទាំងអស់ដែលចេញចូលនៅក្នុងផ្ទះនេះ បានទទួលជីវិតថ្មីដោយសារព្រះហឫទ័យស្រឡាញ់ និងព្រះហឫទ័យមេត្តាករុណា ដែលបងស្រីបានយកចិត្តទុកដាក់អនុវត្ត និងរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រចាំ។ កន្លែងនេះជាកន្លែងមួយពិសេស ដើម្បីអនុវត្តព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ណែនាំឲ្យជីវិតរបស់យើងពោរពេញដោយអំណរសប្បាយ។ សញ្ញាណទីមួយរបស់ព្រះយេស៊ូ កើតឡើងនៅពេលព្រះអង្គចូលរួមពិធីមង្គលការជាមួយគេ ព្រះអង្គបានធ្វើឲ្យទឹកក្លាយទៅជាស្រា ដើម្បីឲ្យភ្ញៀវដែលចូលរួមនៅក្នុងពិធីនោះពោរពេញដោយអំណរសប្បាយ។ ព្រះយេស៊ូយាងមកដើម្បីណែនាំ

ឲ្យយើងមានជីវិត ឲ្យយើងតស៊ូនៅក្នុងសេចក្ដីសង្ឃឹម ពេលយើងមកដល់ផ្ទះបងស្រីមេត្តាករុណា ណែនាំឲ្យយើងយល់ថា ពិតមែនព្រះជាម្ចាស់បានរៀបចំដើម្បីឲ្យបងប្អូនដែលគ្មានទីពឹង អាចរកឃើញគ្រួសារថ្មីមួយ។ ពេលព្រះយេស៊ូបង្ហាញសញ្ញាទីមួយនៅក្នុងមង្គលការ ឲ្យយើងនឹកឃើញថាព្រះសហគមន៍ជាគ្រួសារមួយពិសេស ដូច្នេះឲ្យយើងធ្វើដូចម្ដេចដើម្បីឲ្យព្រះសហគមន៍ទៅជាឪពុកម្ដាយសម្រាប់បងប្អូនឯទៀតៗ។ អ្វីៗដែលបងស្រីធ្វើ គឺធ្វើដោយទឹកចិត្តម្ដាយ ដែលស្រឡាញ់កូន លើកទឹកចិត្តកូន ធ្វើដំណើរជាមួយកូន ថែរក្សាកូនលើកលែងទោសឲ្យកូនជានិច្ច ដើម្បីឲ្យកូនទៅមុខបាន។

ដូច្នេះក្រុមគ្រួសារដែលបានបង្កើតនៅទីនេះ ជាផ្ទះនៃសេចក្ដីសុខសាន្ត ជាផ្ទះនៃសុខសន្តិភាព។ ពេលយើងទាំងអស់គ្នាមកទីនេះម្ដងៗ គឺយើងចូលកន្លែងដែលផ្សេងពីអ្វីដែលយើងឃើញនៅក្នុងសង្គម អ្វីដែលយើងឃើញនៅទីនេះជាសញ្ញាសម្គាល់មួយដ៏អស្ចារ្យ ដែលណែនាំឲ្យសង្គមរបស់យើងដែលវិវឌ្ឍយ៉ាងលឿនត្រូវតែទទួលជានិច្ច។ នៅគ្រប់សម័យសង្គមរបស់យើងអាចរីកចម្រើនដល់ណាក៏បាន ប៉ុន្តែធម៌មេត្តាករុណាត្រូវតែថែរក្សា។ ប្រសិនបើយើងបាត់បងធម៌មេត្តាករុណាប្រសិនបើយើងបាត់បង់លក្ខណៈគ្រួសារដ៏ទូលំទូលាយ ដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ប្រហែលពិភពរបស់របស់យើងលែងមានផ្លូវដើរ។ ប៉ុន្តែយើងដឹងថាយើងមិនអាចបាត់បង់ធម៌មេត្តាករុណា ដោយសារយើងមានព្រះជាម្ចាស់ដែលធ្វើដំណើររួមជាមួយយើង និងបងស្រីដែលបានយកចិត្តទុកដាក់នៅក្នុងនាមព្រះសហគមន៍ ដោយមានអ្នកម្ដាយតេរេសាដែលផ្ដល់កម្លាំង ដើម្បីទៅជាសញ្ញាសម្គាល់ពិសេសសម្រាប់សង្គមបច្ចុប្បន្ននេះ ដូចព្រះយេស៊ូមានសញ្ញាសម្គាល់ពិសេសនៅក្នុងមង្គលការនៅកាណា។ ឲ្យសង្គមនេះចេះនឹកឃើញមនុស្សដែលគ្មានទីពឹងគេទៅណា? មនុស្សដែលគ្មានសេចក្ដីសង្ឃឹមគេទៅណា? តើសង្គមបានរៀបចំផ្លូវមួយណាសម្រាប់គេ? បច្ចុប្បន្នគេឥតមានផ្លូវដែលណែនាំឲ្យគេអាចទៅមុខបាន។ ដូច្នេះព្រះសហគមន៍មានតួនាទី នៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ នៅក្នុងកម្លាំងដែលយើងបានទទួលពីព្រះជាម្ចាស់ យើងអាចធ្វើដំណើរដើម្បីបង្កើតកន្លែង ដើម្បីបង្កើតទីតាំងពិសេសឲ្យបងប្អូនបានទទួលកម្លាំងថ្មី ទទួលជីវិតថ្មីដែលពោរពេញដោយសេចក្ដីសង្ឃឹម។

យើងអរព្រះគុណព្រះជាម្ចាស់ អរគុណបងស្រី ដើម្បីរំឭកឲ្យយើងនៅតាមព្រះសហគមន៍នីមួយៗ នៅតាមកន្លែងរបស់យើងឲ្យយើងធ្វើយ៉ាងដូចម្ដេច ដើម្បីថែរក្សាធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជានិច្ច ដោយនឹកឃើញដល់មនុស្សដែលគ្មានទីពឹង ដើម្បីរស់នៅនៅក្នុងមហាគ្រួសារនៃព្រះសហគមន៍។ យើងទូលអង្វរតាមរយៈសន្តីតេរេសានៃទីក្រុងហ្គាល់ហ្គូតា ឲ្យព្រះសហគមន៍របស់យើងចេះធ្វើជាម្ដាយជាឪពុក ដើម្បីលើកទឹកចិត្ត ដើម្បីណែនាំឲ្យមនុស្សយ៉ាងច្រើនបានទទួលការសង្គ្រោះដោយសារព្រះហឫទ័យស្រឡាញ់ និងព្រះហឫទ័យមេត្តាករុណា។ យើងត្រូវ

ការមានទឹកចិត្តម្តាយជានិច្ច ដើម្បីណែនាំឲ្យយើងមានចិត្តមេត្តាករុណាដូចព្រះជាម្ចាស់ ឲ្យយើងសម្លឹងមើលម្តាយតែរសោថែមទៀត ដោយដឹងថាយកចិត្តទុកដាក់ដោយថែរក្សាភាពស្ងៀមស្ងាត់ដើម្បីអធិដ្ឋាន នៅពេលយើងអធិដ្ឋានយើងពោរពេញដោយជំនឿ ពេលយើងពោរពេញដោយជំនឿយើងពោរពេញដោយសេចក្តីស្រឡាញ់ ពេលយើងពោរពេញដោយសេចក្តីស្រឡាញ់យើងយើងជាអ្នកបម្រើ។ នេះជាអ្នកម្តាយដែលបានណែនាំយើង និងបានថែរក្សាយើងជានិច្ច ដើម្បីឲ្យព្រះសហគមន៍ទៅជាទីតាំងមួយយ៉ាងពិសេស ដែលយើងអាចមានបទពិសោធជាក់ស្តែងអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ អាម៉ែន៕